គំនិតឡេះឡោះ

គំនិតឡេះឡោះ

ក្នុងរយៈពេល ប៉ុន្មានខែនេះ លោក សម រង្សី គាត់ធ្វើ សកម្មភាពចម្លែក គឺថា ដំបូង បានប្រកាសជាឧឡារិក នូវ វិធានការបីយ៉ាង សំរាប់ សង្គ្រោះ គណបក្សសង្គ្រោះជាតិ គឺ :

បដិសេធ នូវការវិនិច្ឆ័យ របស់តុលាការ, រក្សា នូវរចនាសម្ព័ន្ធ គណបក្ស និង បំរុងនឹង ចរចាជាមួយគូបដិបក្ស។ បន្ទាប់មក គាត់ចង់បង្កើត ចលនា តំកើង លទ្ធិប្រជាធិបតេយ្យ ដោយ បញ្ជាក់ថាជាចលនា មិនធ្វើនយោបាយ។ ក្រោយមកទៀត គាត់រៀបចំបង្កើត ចលនាសង្គ្រោះជាតិ អនយោបាយ ដែរ។

ចំពោះ បក្សពួកលោក សម រង្សី ពួកគាត់ យល់ឃើញថា សកម្មភាពញ៉ាទទ្រើតនេះ វាស្ថិតនៅក្នុង ដំណើរ មានហេតុផល ក្នុង គោលដៅតែមួយ គឺ សង្គ្រោះ គណបក្សសង្គ្រោះជាតិ ព្រោះ ថា គណបក្សនេះ ស្ថិតនៅក្នុងស្ថានភាពទំនាល់។

យើងលើកយកសាច់រឿង (scénario) បីយ៉ាង មកពិចារណា ដើម្បី រកការយល់ដឹងពីស្ថានភាពនយោបាយសព្វថ្ងៃ។

១. គណបក្សសង្គ្រោះជាតិ ស្លាប់នយោបាយ តាំងពី ពួកអ្នក ដឹកនាំ សម្រេចចិត្ត ចូលរួមប្រជុំ រដ្ឋសភា នៅឆ្នាំ ២០១៤។ ការ សម្រេចចិត្តនេះ ផ្តល់ ក្រាប់មធ្យោបាយ ១លោក ហ៊ុន សែន មាន

កំនិតឡេះឡោះ

ដំរួយគ្រប់បែបយ៉ាង តាមច្បាប់ សំរាប់ពង្រឹង អំណាចផ្តាច់ការ បន្ថែមទៀត។ ដូច្នេះ ស្ថានភាពសព្វថ្ងៃ វាគ្រាន់តែជា កម្មវិបាក នៃ កំនិតឃ្លៀងឃ្លាត របស់ពួកអ្នកដឹកនាំ គណបក្សសង្គ្រោះជាតិនោះឯង។ រឬធម៌សន្ទនា ខ្ទះមធ្យោបាយ វាគ្រាន់តែជា រឬធម៌ចុះចាញ់តែប៉ុណ្ណោះ។ ក្នុង ករណីនេះ ពួកអ្នកដឹកនាំ គណបក្សសង្គ្រោះជាតិ បានបួររូប សន្ធឹកឆ្នោតបីលាន ជា កម្លាំងនយោបាយរបស់ខ្លួន ទៅជា មធ្យោបាយ រកប្រយោជន៍ផ្ទាល់ខ្លួន ទៅវិញ។ ភាពកម្ម នៃសុភនិច្ឆ័យ នៅក្នុង រដ្ឋសភា វាប្រែក្លាយជា ការរួមកំនិត ជាមួយ គណបក្សកាន់អំណាចប្រឆាំងនឹង លទ្ធិប្រជាធិបតេយ្យ តែម្តង។

២. គណបក្សសង្គ្រោះជាតិ ជា គណបក្សរងគ្រោះ ពីសំណាក់អំណាចផ្តាច់ការ។ គឺមានន័យថា អ្វីដែលបានធ្វើ គឺជា យុទ្ធសាស្ត្រនយោបាយក្រឹមត្រូវ ដែលជាដំណើរទៅរកជ័យជំនះស្ងាន់នៅឆ្នាំ ២០១៨។ ហេតុនេះឯង ដែលនាំឲលោក ហ៊ុន សែន ភ័យខ្លាច ហើយចាត់វិធានការទុបជាមុន គឺ ចាប់ លោក កឹម សុខា ដាក់គុក និង រំលាយ គណបក្សចោលតែម្តង។ សាច់រឿងទុកខ្លួនជា អ្នករងគ្រោះ ក៏ជា កម្មវិបាក នៃ ការយល់ឃើញថា យុទ្ធសាស្ត្រនយោបាយ របស់ពួកអ្នកដឹងនាំ គណបក្សសង្គ្រោះជាតិ ជា ទង្វើយុត្ត: (action juste) ព្រោះនាំឲលោក ហ៊ុន សែន វាយប្រហារ។ តែការទុកខ្លួន ជាអ្នករងគ្រោះ គឺ ទុកខ្លួន ជាអ្នកខ្សោយរួចស្រេចទៅហើយ ដែលវាផ្ទុយនឹង កំនិតខ្លួនថា ជា

គំនិតឡេះឡោះ

កម្លាំងនយោបាយ អាចឈ្នះឆ្នោតនៅឆ្នាំ ២០១៨។ បើខ្សោយ តើមានកម្លាំងរូបី ឬ អរូបី អ្វីខ្លះ ដែលអាចយកវាមកប្រើ ដើម្បីការពារជ័យជំនះខ្លួនបាន នៅពេល ឈ្នះឆ្នោត។ គណបក្ស នយោបាយ ដែលមានប្រជាជនខ្មែរស្ទើទាំងអស់ គាំទ្រ តែទុកខ្លួន ជា អ្នករងគ្រោះ គឺដូចជាប្រាប់ខ្មែរថា ខ្លួនមិនទទួលខុសត្រូវ លើ សេចក្តីទុកចិត្ត របស់ខ្មែរចំពោះខ្លួននោះឡើយ។ គណបក្សសង្គ្រោះជាតិ មានមហិច្ឆិតា ច្បាស់លាស់ គឺ សង្គ្រោះប្រជាជាតិខ្មែរ ដែលកំពុងរងគ្រោះនឹង អំណាចយួន និង ខ្មែរយួន តែ បែរជាទុកខ្លួន ជាអ្នករងគ្រោះដែរ ដូចនេះ គេអាច សួរថា តើអ្នកណា សង្គ្រោះអ្នកណា ? បរទេស ជា អ្នកសង្គ្រោះប្រជាជាតិខ្មែរ ? ដូចសព្វថ្ងៃនាំគ្នាដេកចាំ អាមេរិកាំង និង សហគមអឺរ៉ុប នោះឯង តែការរង់ចាំបែបនេះ គឺជាការរង់ចាំយូរអង្វែងណាស់សំរាប់ខ្មែរ រស់នៅក្នុងទ្រុងយួន។

ទី៣. លោក សម រង្សី ជា អ្នកសង្គ្រោះ ប្រជាជាតិខ្មែរ។ ត្រូវដឹងថាលោក សម រង្សី ជាអ្នកចាញ់លោក ហ៊ុន សែន រហូត ហើយ បរាជ័យរបស់គាត់ សុទ្ធតែជាកំហុសផ្ទាល់ខ្លួនរបស់គាត់ ដែលខ្លួនគាត់ មិនទាំងដឹងខ្លួនផង ព្រោះប្រព័ន្ធ នៃគំនិតរបស់គាត់ គឺជា អនុប្រព័ន្ធ នៃ សីហនុនិយម គឺថា ‹អញជាព្រះ› ព្រោះព្រះមិនអាចមានកំហុសទេ។ ស្រុកខ្មែរ ក្លាយជាស្រុកខ្ជុំយួន តែចំពោះ លោក សម រង្សី គាត់នៅតែអាច ថ្លែងហួសវិស័យថា ‹ *បើ សម្តេចសីហនុ នៅរស់ ច្បាស់ជា លោក ហ៊ុន សែន មិន*

គំនិតឡេះឡោះ

អាចធ្វើដូចសព្វថ្ងៃបាននោះឡើយ។ លោក សម រង្សី មិនដែលបានគិតថា យួន ខ្មែរយួន និង យួនខ្មែរ គេអាចធ្វើអ្វីបានសម្រេចទាំងអស់ ដោយសារតែមានសម្តេច សីហនុ នេះឯង ជាអ្នកជួយទាំងស្រុង តាំងតែពីឆ្នាំ ១៩៦៥ មកម្លេះ។ លោក សម រង្សី គាត់មានសំណាង កម្រមានណាស់ សំរាប់ជីវិតអ្នកស្នេហាជាតិ គឺគាត់មាន ប្រជាប្រិយភាពពិត លើនាកនយោបាយជាតិ តែគាត់ មិនយក លាភជ័យនេះ ដែលជា មធ្យោបាយ ដ៏ត្រកាល ប្រើ សំរាប់បំរើប្រជាជាតិ បែរជាហុចឲលោក ហ៊ុន សែន យកទៅប្រើ សំរាប់រក្សាអំណាច ដើម្បីបោយយកប្រយោជន៏។ លាភជ័យនេះ ជា ឱកាសល្អកំហុកមួយ សំរាប់ប្រជាជាតិ ដែលនឹងកម្រមានកើតម្តងទៀត ព្រោះខ្មែរ លែងមានសេចក្តីទុកចិត្តលើអ្នកដឹកនាំរតាមខ្យល់។ ដូច្នេះ លោក សម រង្សី មិនខុសពី ទ្រង់ រណ្ណាឫទ្ធិ គឺថា ដូចស្វាបានផ្លែដូង មិនដឹងធ្វើ យ៉ាងដូចម្តេច នឹងអាចផឹកទឹកដូងបាន។ ចំពោះ ករណីផ្ទាល់របស់លោក សម រង្សី គាត់ ទទួលបរាជ័យ រហូតដល់សុំលាឈប់ពីតំណែង ប្រធាន និង សមាជិកបក្ស ដោយហេតុផ្ទាល់ខ្លួន។ មូលហេតុនេះ គឺហាក់បី លោក សម រង្សី ទទួលសារភាព ថា គាត់ គ្មានទំនាស់នយោបាយអ្វី ជាមួយលោក ហ៊ុន សែន នោះឡើយ។ ត្រូវដឹងថា របៀប ចាត់ការ និង សេចក្តីសម្រេច របស់លោក សម រង្សី គឺជា របៀប ‹ខុនណាង› (épouse mandarin) ខ្មែរ យើងច្រើននិយាយថា ‹ប្តីស័ក្តិបី ប្រពន្ធស័ក្តិប្រាំ›។ គាត់ចាំស្តាប់តែភរិយាគាត់សម្រេច រីឯភរិយាគាត់វិញ ចាប់ស្តាប់តែ ពួក

គំនិតឡេះឡោះ

អ្នកកំរៃជើងសារ (commissionnaires) របស់លោក ហ៊ុន សែន មកស្នើ ឬ ក្រៀងគរ គូស្វាមីថា បើលោកទាំងពីរ ធ្វើដូច្នេះ ទើបអាច សម្តេច យល់ព្រមបាន ពោលថា បើធ្វើ ដូចសម្តេចចង់បាន គឺលោកទាំងពីរ នឹងទទួលបានប្រយោជន៍ ជាពុំខាន។ តែ លោក ខុនណាង គាត់ភ្លេចថា ប្រយោជន៍ ដែលលោក ហ៊ុន សែន ប្រគល់ឲគាត់ និង ស្វាមី វាជារបស់ ហ៊ុន សែន និង យួនទាំងអស់ ពោលថា ‹ឲបាន តែក៏អាចយកវិញបានដែរ›។ ដូចនេះ ការបង្កើត ចលនាសង្គ្រោះជាតិ គឺជា ការបន្ត រកប្រយោជន៍ផ្ទាល់ខ្លួន របស់លោក សម រង្សី និង ខុនណាង និង បក្សពួកតែប៉ុណ្ណោះ ព្រោះវាគ្មានឃើញអ្វីបន្ទិចសោះ ដែលអាចចាត់ទុកជា កម្លាំងបន្ថែម ឬ ការស្តាបនាតម្លៃថ្មី សំរាប់សង្គ្រោះ គណបក្សសង្គ្រោះជាតិនោះឡើយ។ ផ្ទុយទៅវិញ មានតែបង្ហាញជាក់ស្តែង នូវ ការបែកបាក់ផ្ទៃក្នុងទៅវិញ។ គំនិតឡេះឡោះនេះ គឺជា សញ្ញាការណដ្ឋាន(marque de fabrique) របស់លោក សម រង្សី និង ខុនណាង នោះឯង។ ជាងពីរទសវត្សរ៍ មកហើយ លោក សម រង្សី គាត់សារភាពថា គាត់ធ្វើតាម នូវការចង់បានរបស់លោក ហ៊ុន សែន ជានិច្ច។ ថ្មីៗនេះ គាត់ប្រាប់ វិទ្យុ អាស៊ីសេរី ថា គាត់ឈប់ធ្វើតាមទៀតហើយ តែទង្វើសព្វថ្ងៃ របស់គាត់ វាផ្ទុយពីសំដីរបស់គាត់ទាំងស្រុង ព្រោះ ចលនាបង្កើតថ្មីនេះ គឺជា បំណងរបស់លោក ហ៊ុន សែន ដែល លោក សម រង្សី ផ្តល់ជូន ដើម្បី ទុក ចលនា ជា អវកាស (espace) សំរាប់ លោក ហ៊ុន សែន និង សម រង្សី ចរចាគ្នា មិនមែន សំរាប់ដោះស្រាយ

គំនិតឡេះឡោះ

បញ្ហានយោបាយនោះទេ គឺសំរាប់រៀបចំ នូវការបោះឆ្នោតមួយ ដែលអាចឲ្យ បរទេស មួយចំនួន ទទួលស្គាល់បាន។ ដូច្នេះ លោក សម រង្សី ឬ ខុនណាង ទោះបីមានឈ្មោះ នៅក្នុងបញ្ជី បុគ្គល ក្មានសិទ្ធិធ្វើនយោបាយក៏ដោយ តែអាចចូលរួម ដោះស្រាយ យុទ្ធសាស្ត្រ នៃ ការបោះឆ្នោត បដិលទ្ធិប្រជាធិបតេយ្យ ព្រោះអ្វី ដែលលោក ហ៊ុន សែន បានស្តោះហើយ គាត់មិនអាចលេប បានវិញទេ ដូច្នេះ ត្រូវឈប់និយាយពីបញ្ហា លោក កឹម សុខា គណបក្សសង្គ្រោះជាតិ និង ពួកបុគ្គល នៅក្នុងបំរាម មិនឲ្យធ្វើ នយោបាយ។ ដំណោះស្រាយបែបនេះ ចំពោះលោក ហ៊ុន សែន វា ជាទង្វើ ក្មានអ្នកអាម៉ាស់មុខ។ ដូច្នេះ សិថិលភាព (concession ou compromis) នេះ គឺជា ការបើកទ្វារចំហឲ្យ អតីតសមាជិក នៃគណបក្សសង្គ្រោះជាតិ មានចិត្តចង់ជួយលោក ហ៊ុន សែន ចូលជាសមាជិក ចលនាសង្គ្រោះជាតិ ដែលជា អនយោបាយ ដែលមាន លោក សម រង្សី ឬ ខុនណាង ជាអ្នកប្រមូល។ រីឯ សហរដ្ឋអាមេរិក និង សហគមអឺរ៉ុប ក៏គេនាំគ្នា ពន្យាសកម្ម ភាព របស់គេ បន្តប្រឆាំងនឹងលោក ហ៊ុន សែន សិនទៅ ព្រោះ គេយល់ឃើញថា ប្រជាពលរដ្ឋខ្មែរ ហាក់បីដូចជា អាចបន្តរស់ បាន នៅក្នុងរបបផ្តាច់ការនៅស្រុកខ្មែរ ព្រោះ វាក្មានប្រតិកម្ម ជាក់ស្តែងអ្វីប្រឆាំងនឹង អំណាចនេះឡើយ។ ត្រូវដឹងថា អ្នក ដែលមានជ័យជំនះដាច់ខាត គឺ យៀកណាម នោះឯង។